00317553

E39/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 04 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ

**Case File/Dossier No. 001/18-07-2007/ECCC/TC**

| | |
|---|---|
| នៅចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៩ |
| ចំណាត់ថ្នាក់នៃឯកសារ: | សាធារណៈ |

---

# សេចក្តីសម្រេចពន្យារយៈពេលកំណត់ ដើម្បីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទនៅក្រៅឃុំ

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Robert PETIT

**<u>ជនជាប់ចោទ</u>**
កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**<u>មេធាវីការពារក្តី</u>**
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARES

00317554

E39/4



**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”)។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង អនុលោមតាម “សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច” ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨ (សេចក្តីសម្រេច)[1]។

**ក្រោយពីបានស្តាប់** សំណើសុំដោយផ្ទាល់មាត់ពីមេធាវីការពារក្តីកាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៩ ដែលបានស្នើសុំអោយដោះលែងជនជាប់ចោទនៅក្រៅឃុំដោយមានលក្ខខណ្ឌ[2]។

**ក្រោយពីបានទទួល** ច្បាប់ចំលងមួយច្បាប់នៃសំណុំរឿងក្តីប្រឆាំងនឹងជនជាប់ចោទពីតុលាការយោធា។

**បានឃើញ** សេចក្តីសង្កេតជាលាយលក្ខណ៍អក្សរដែលបានដាក់ដោយមេធាវីការពារក្តីកាលពីថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩[3]។

**អនុលោមតាម** វិធាន ៨២(៣) នៃវិធានផ្ទៃក្នុង។

---

[1] “សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច”, ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០០៨ (ឯកសារ D99/3/42)

[2] “កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធីសវនាការ”, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ (ឯកសារ E1/7) និង “ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ” ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៩ (ឯកសារ E1/7.1) ទំព័រទី ២០ បន្ទាត់ទី ០១ ដល់ទំព័រទី ៣២ បន្ទាត់ទី ១៩ ក្នុងភាសាអង់គ្លេស។

[3] “អំណះអំណាងបន្ថែមដែលបានលើកដោយមេធាវីការពារក្តីដើម្បីផ្តល់ការគាំទ្រដល់ការស្នើសុំរបស់ខ្លួនទាក់ទងនឹងបញ្ហានៃទោស” ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩ (ឯកសារ E39/3)

00317555

E39/4

០០១/១៨ កក្កដា ២០០៧/អវតក/អជសង

**ចេញសេចក្ដីសម្រេចដូចខាងក្រោមនេះ៖**

១. នៅថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើដោយផ្ទាល់មាត់របស់ មេធាវីការពារក្ដីដែលស្នើសុំឱ្យដោះលែងជនជាប់ចោទនៅក្រៅឃុំ។

២. អនុលោមតាមវិធាន ៨២(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង "ត្រូវសម្រេចឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងនៅក្នុងគ្រប់ករណីទាំងអស់ត្រូវសម្រេច ក្នុងរយៈពេលមិនឱ្យលើសពី៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានពាក្យសុំដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ លើកលែងតែមានកាលៈទេសៈពិសេស ដែលតម្រូវឱ្យមានរយៈពេលយូរជាងនេះ"។

៣. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា សំណើសុំឱ្យដោះលែងបានធ្វើឡើងដោយផ្អែកលើការចោទប្រកាន់ជាច្រើន ដែលក្នុងចំណោមការចោទប្រកាន់ទាំងនោះមានការចោទប្រកាន់ដែលថាការឃុំខ្លួនជនជាប់ចោទត្រូវបានពន្យារពេលដោយមិនត្រឹមត្រូវ និងថាការឃុំខ្លួននៅអ.វ.ត.ក គឺជាការបន្តការឃុំខ្លួនរបស់តុលាការយោធា។ ដើម្បីវាយតម្លៃលើការចោទប្រកាន់ទាំងនេះអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គជំនុំជម្រះត្រូវពិនិត្យមើលសំណុំរឿងរបស់តុលាការយោធា។

៤. នៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០០៩ តាមរយៈការិយាល័យរដ្ឋបាល អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំតុលាការយោធាឱ្យផ្ដល់សំណុំរឿងទាក់ទងនឹងការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធា។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ ប្រធានអង្គជំនុំជម្រះសាលាដំបូងទទួលបានច្បាប់ចម្លងនៃសំណុំរឿងរបស់តុលាការយោធាពីការិយាល័យរដ្ឋបាល។

សំណុំរឿងទាំងមូលត្រូវបានសរសេរជាភាសាខ្មែរ ហើយបានស្នើសុំឱ្យបកប្រែជាភាសាអង់គ្លេស និងភាសាបារាំង។

៥. ផ្នែកបកប្រែបានជម្រាបជូនអង្គជំនុំជម្រះថា ការបកប្រែឯកសារទាំងនេះ ជាភាសាអង់គ្លេស និងភាសាបារាំងនឹងត្រូវបកប្រែរួចនៅថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០០៨។

៦. លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្តីបានដាក់សារណាជាលាយលក្ខណ៍អក្សរដែលគាំទ្រដល់សំណើរបស់ខ្លួន ជាភាសាខ្មែរ និងបារាំង នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨ ពោលគឺ១០ ថ្ងៃបន្ទាប់ពីការស្នើសុំលើកដំបូង។

៧. ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញមានការឈប់សម្រាកមួយសប្តាហ៍ចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០០៨ និងការឈប់សម្រាកនាពេលខាងមុខចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០០៨។

៨. ក្រោយពីទទួលបានសំណៅបកប្រែសំណុំរឿងរបស់តុលាការយោធា ភាគីនានាមានរយៈពេល ១០ ថ្ងៃ ដើម្បីផ្តល់មតិយោបល់របស់ខ្លួន។

៩. ដើម្បីផ្តល់ឱ្យភាគីនានាមានពេលវេលាគ្រប់គ្រាន់សម្រាប់ឆ្លើយតប និងដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចមួយដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់និងមានសំអាងហេតុច្បាស់លាស់ អង្គជំនុំជម្រះយល់ឃើញថា មានកាលៈទេសៈពិសេស ដែលតម្រូវឱ្យមានការពន្យាររយៈពេលកំណត់ដើម្បីចេញសេចក្តីសម្រេចលើសំណើសុំឱ្យដោះលែងជនជាប់ចោទនៅក្រៅឃុំបាន។

## ហេតុដូច្នេះសម្រេច

១-បន្ថែមរយៈពេលកណត់ចំនួន ៤៥ ថ្ងៃទៀតលើរយៈពេលដែលបានកំណត់ក្នុងវិធាន ៨២(៣)។

00317557

E39/4



២-ថាអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទនៅក្រៅឃុំនេះ យ៉ាងយូរត្រឹមថ្ងៃទី ១៥ មិថុនា ឆ្នាំ ២០០៩។

ភ្នំពេញ ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៩

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល - ណុន